**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការក្រសួងយុត្តិធម៌**

លេខៈ ៣៤៤.ក.យ.ប្រក/០៧

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ សីហា ឆ្នាំ ២០០៧

# ប្រកាស

## ស្តីពី

## បែបបទ និងនីតិវិធី នៃការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមការចាំបាច់

**ស ម្រេ ច**

**ប្រការ ១ :**

ត្រូវបានទទួលនូវគុណសម្បត្តិ ជាភ្នាក់ងារនគរបាលយុត្តិធម៌ ចំពោះមន្ត្រីនគរបាល កងរាជអាវុធហត្ថ យោធិន ដែលចាំបាច់ក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសព្រហ្មទណ្ឌ ៖

១- នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ។

២- ភ្នាក់ងារនគរបាលជាតិផ្សេងទៀត ។

៣- នាយទាហាននៃកងរាជអាវុធហត្ថ ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ។

៤- យោធិនផ្សេងទៀតនៃកងរាជអាវុធហត្ថ ។

**ប្រការ ២ :**

មុននឹងបំពេញមុខងារ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវធ្វើសម្បថនៅចំពោះមុខសាលាដំបូង ទៅតាមបែបបទ និងរូបមន្ត ដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ៣ :**

ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

**ប្រការ ៤ :**

ប្រធានសាលាដំបូង និងព្រះរាជអាជ្ញាអមសាលាដំបូងគ្រប់ខេត្ត-ក្រុង និងស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍានៈ

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- តុលាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍
- តុលាការ និងអយ្យការសាលាដំបូងខេត្ត-ក្រុង
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

*ឧបសម្ព័ន្ធនៃប្រកាសលេខ ៣៥ កយ.ប្រក / ០៧ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៧*

# <u>នីតិវិធី</u>

## <u>នៃការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌</u>

១- ក្រឡាបញ្ជី ជាអ្នកចាត់តាំងកម្មវិធី :

- ហៅឈ្មោះអ្នកដែលចូលធ្វើសម្បថម្នាក់ម្តងៗ ចូលក្នុងសាលពិធី
- ប្រកាសបើកពិធីធ្វើសម្បថ ភ្នាក់ងារនគរបាលយុត្តិធម៌
- ប្រកាសសមាសភាព ក្រុមប្រឹក្សា តំណាងអយ្យការ និងក្រឡាបញ្ជី :

☞ តំណាងតុលាការ

- លោក............................ ប្រធានសាលាដំបូង

☞ តំណាងអយ្យការ

- លោក........................... ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង

☞ ក្រឡាបញ្ជី

- លោក........................... ក្រឡាបញ្ជីនៃពិធី

២- ក្រឡាបញ្ជីអានបញ្ជីឈ្មោះអ្នកដែលត្រូវស្បថ

៣- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

៤- តំណាងភ្នាក់ងារនគរបាលយុត្តិធម៌ម្នាក់ អាន **ប្រការសច្ចាប្រណិធាន** ( ឱ្យអ្នកស្បថថាតាមខ្លាំងៗ )

៥- ប្រធានក្រុមប្រឹក្សា អាន **សច្ចាប្រណិធាន** ( ឱ្យអ្នកស្បថលើកដៃស្តាំដាក់ត្រឹមត្រចៀក និងថាតាមខ្លាំងៗ )

៦- មតិផ្តាំផ្ញើ របស់តំណាងអយ្យការ

៧- មតិផ្តាំផ្ញើ របស់ប្រធានក្រុមប្រឹក្សា

៨- ចប់កម្មវិធី

*<u>សំគាល់:</u> អ្នកស្បថទាំងអស់ ត្រូវចុះហត្ថលេខាលើកំណត់ហេតុ និងផតចំលងកំណត់ហេតុជូនសាមីខ្លួនម្នាក់ៗ*

## ប្រណិធាន (សេចក្តីអំពាវនាវ)

៤៤៦៣

បពិត្រអស់ទេពារ័ក្ស អារុក្ខអារក្ស អ្នកតា និងបារមីដ៏សក្តិសិទ្ធិ មាន : ព្រះអង្គដង្កើរ ព្រះអង្គក្រពុំឈូក ព្រះអង្គ ស្វេតច្ឆ័ត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវ័រវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្វែងជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថ ត្បិតយើងខ្ញុំបានចូលខ្លួនមកសុំធ្វើសម្បថសច្ចាប្រណិធាន ដើម្បីបំពេញតួនាទីជាភ្នាក់ងារនគរបាលយុត្តិធមិនាពេលនេះ ។

បើយើងខ្ញុំប្រព្រឹត្តល្មៀងឃ្លាងឃ្លាតចាកច្បាប់ មិនអនុវត្តត្រឹមត្រូវតាមច្បាប់ ដោយមានចេតនាទុច្ចរិត សូមអស់ទេពារ័ក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិទាំងអស់ បំផ្លាញយើងខ្ញុំឱ្យវិនាសលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង ខ្សែភ្លើងឆក់ រន្ទះបាញ់ ឡានម៉ូតូបុក ខ្លាខាំ ពស់ចឹក លុះអានាគតជាតិ ឱ្យព្រាត់ប្រាស់ និរាសឪពុកម្តាយ បងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់ប្រាំរយជាតិ ។

បើយើងខ្ញុំប្រព្រឹត្តល្អទៀងត្រង់ ត្រឹមត្រូវតាមគន្លងច្បាប់ យកចិត្តទុកដាក់ប្រឹងប្រែងអនុវត្តការងារ ដោយស្មោះត្រង់ អស់ពីចិត្តពីថ្លើម សូមអស់ទេពារ័ក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិក្នុងលោក ជួយឱ្យយើងខ្ញុំ មានអាយុវែងយឺនយូរ មានសេចក្តីសុខដុមរមនា មានសុខភាពល្អ មានទ្រព្យសម្បត្តិ មាស ប្រាក់ កែវកង ពិទូរ្យសូរ្យកាន្ត សម្បូរហូរហៀរ លុះអនាគតជាតិ បានជួបតែសេចក្តីល្អ មានទ្រព្យស្តុកស្តម្ភ កិត្តិយសថ្លៃថ្នូរ ចម្រុងចម្រើន ថ្កុំថ្កើងរុងរឿង សមដូចសេចក្តីបំណងប៉ងប្រាថ្នា កុំបីអាក់ខានឡើយ ។

# ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមសច្ចាប្រណិធានថា នឹងអនុវត្តវិជ្ជាជីវៈ ជាភ្នាក់ងារនគរបាលយុត្តិធម៌របស់ខ្ញុំ ដោយសេចក្តីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយសេចក្តីទៀងត្រង់ ដោយមនុស្សធម៌ ដោយស្មារតីឯករាជ្យ និងដោយគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ជាដរាបតរៀងទៅ ។